**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ**

# ការវិភាគរបស់នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃលើការគណនា ថ្លៃលក់អគ្គិសនីសំរាប់តំបន់ចែកចាយថ្មី របស់អគ្គិសនីកម្ពុជា នៅទីរួមខេត្តកំពត

## ១-សេចក្តីផ្តើម

អាជ្ញាធរអគ្គិសនីកម្ពុជាបានទទួលលិខិតរបស់អគ្គិសនីកម្ពុជាលេខ៣៩៨៣លស-អក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ ។ បន្ទាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យសំណុំឯកសារស្នើសុំកំណត់ថ្លៃលក់អគ្គិសនីនៅទីរួមខេត្តចំនួន៨ ដែលជាតំបន់ធ្វើសេវាកម្មថ្មីរបស់អគ្គិសនីកម្ពុជាមកឃើញថា ពត៌មានដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរមានចំណុចមួយចំនួនពុំទាន់ច្បាស់លាស់ដែលអាចឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការវាយតម្លៃបាននៅឡើយ ។ ដើម្បីឱ្យការពិនិត្យនិងវាយតម្លៃ អាចដំណើរការបានឆាប់ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានផ្ញើលិខិតទៅអគ្គិសនីកម្ពុជាស្នើផ្តល់ឯកសារបន្ថែម និងចាត់មន្ត្រីជំនាញមកពិភាក្សាគ្នានៅស្នាក់ការអាជ្ញាធរអគ្គិសនីកម្ពុជា ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥ អាជ្ញាធរអគ្គិសនីកម្ពុជានិងអគ្គិសនីកម្ពុជាបានបើកការប្រជុំពិភាក្សាស្តីពីការកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ។ បន្ទាប់មកអគ្គិសនីកម្ពុជាបានរៀបចំឡើងវិញនិងស្នើសុំកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ជាថ្មី តាមលិខិតលេខ៦០២លស-អក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ។ ពត៌មាន ដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរជាលើកទី២នេះ មានលក្ខណៈគ្រប់គ្រាន់និងសមស្របសំរាប់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការសិក្សានិងវាយតម្លៃបាន ។ <u>ដូច្នេះ នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ នៃអាជ្ញាធរអគ្គិសនីកម្ពុជា សូមធ្វើការវិភាគលើការគណនាថ្លៃលក់អគ្គិសនីនៅទីរួមខេត្តកំពត ដូចតទៅ</u> :

## ២-ការសង្កេតនិងវិភាគ

### ២.១- ទុនវិនិយោគ

- ទុនវិនិយោគផ្នែកផលិតកម្មដែលមានរោងចក្រអគ្គិសនីអានុភាព 2000kW ចំណាយទុនអស់ចំនួន **1,374,034** ដុល្លារអាមេរិច និងទុនវិនិយោគផ្នែកចែកចាយចំនួន **1,854,107** ដុល្លារអាមេរិច ។ ការវិនិយោគនេះមានទ្រង់ទ្រាយធំនិងមានតម្លៃខ្ពស់ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនអគ្គិសនីឯកជនផ្សេងទៀត នេះសរបញ្ជាក់ឱ្យឃើញថា គុណភាពនៃមធ្យោបាយផលិត និងមធ្យោបាយចែកចាយ

ពិតជាល្អ ដូច្នេះ អាយុកាលរំលោះរបស់វាក៏វែងដែរ និងអត្រាប្រើប្រាស់ប្រេងឥន្ធនៈល្អគឺ 210g/kWh ។

- ការកំណត់អាយុកាលរំលោះ១៨ឆ្នាំសំរាប់រោងចក្រអគ្គិសនី និង២៥ឆ្នាំសំរាប់ខ្សែបណ្តាញ អាជ្ញាធរអាចទទួលយកបាន ។

## ២.២- ការប្រាក់

អត្រាការប្រាក់ស្មើនឹង 3.5% ក្នុង១ឆ្នាំ គឺជាអត្រាមួយត្រឹមត្រូវយោងតាមកិច្ចព្រមព្រៀងខ្ចីបន្តរបស់អគ្គិសនីកម្ពុជាជាមួយរាជរដ្ឋាភិបាល ប៉ុន្តែអគ្គិសនីកម្ពុជាបានគណនាចំណាយការប្រាក់នេះលើទុនវិនិយោគសរុបដែលរួមមានប្រាក់កម្ចីនិងមូលធនផ្ទាល់ ស្មើនឹង 197,173,893 រៀល សំរាប់ផ្នែកផលិតកម្ម និង 266,064,349 រៀល សំរាប់ផ្នែកចែកចាយ ។ ចំណាយការប្រាក់ដែលត្រឹមត្រូវគឺត្រូវគណនាលើប្រាក់កម្ចីសរុបបន្ទាប់ពីសាងសង់រួចដោយគិតរួមទាំងការប្រាក់ក្នុងពេលសាងសង់ ប៉ុន្តែមិនគិតបន្ថែមនូវមូលធនផ្ទាល់នោះទេ ។ ដូច្នេះ ចំណាយការប្រាក់ត្រឹមត្រូវសំរាប់ផ្នែកផលិតកម្មស្មើនឹង 196,958,643 រៀល និងផ្នែកចែកចាយស្មើនឹង 260,017,949 រៀល ក្នុងឆ្នាំ២០០៥ និងថយចុះជាលំដាប់នៅឆ្នាំបន្តបន្ទាប់ ។

## ២.៣- ទិន្នន័យផលិតកម្ម

ទិន្នន័យផលិតកម្មដែលផ្តល់ដោយអគ្គិសនីកម្ពុជាអាចទទួលយកបាន ប៉ុន្តែមានចំណុចពីរដែលអគ្គិសនីកម្ពុជាគិតច្រឡំគឺថាមពលប្រើប្រាស់ក្នុងផលិតកម្មគឺ 3.5% ប៉ុន្តែនៅឆ្នាំ២០០៧ គិតតែ 3 % ដូច្នេះអាជ្ញាធរកែមក 3.5% ចំណែកអត្រាបាត់បង់ថាមពលវិញ EDC បានគិតអត្រានេះ ធៀបទៅនឹងថាមពលផលិតស្មើនឹង 11.50% ពុំត្រឹមត្រូវទេ ការគណនាអត្រាបាត់បង់គឺត្រូវធៀបទៅនឹងបរិមាណថាមពលបញ្ចេញឱ្យបណ្តាញចែកចាយ ។ ដូច្នេះអត្រាបាត់បង់ស្មើនឹង 11.92% ។

- អត្រាប្រើប្រាស់ប្រេងឥន្ធនៈគឺ 210g/kWh
- អត្រាប្រើប្រាស់ប្រេងរំអិលគឺ 0.001g/kWh
- ថ្លៃប្រេងឥន្ធនៈរួមទាំងថ្លៃដឹកជញ្ជូន 530USD ក្នុង១តោន
- ថ្លៃប្រេងរំអិល 415USD ក្នុង១ធុង

អត្រាខាងលើនេះ សមរម្យ និងអាចទទួលយកបានសំរាប់សិក្សាថ្លៃដើម ។

## ២.៤- ចំណាយផ្នែកផលិតកម្ម

បុគ្គលិកសរុបមានចំនួន២៦នាក់ ដែលមានប្រាក់ខែជាមធ្យមប្រហែលនឹង95USD ក្នុង១នាក់ គឺសមស្របអាចទទួលយកបាន ។ ចំណែកឯចំណាយដំណើរការនិងការថែទាំ ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ ស្មើនឹង 55,989,600 រៀល និង 65,345,249 រៀល ក្នុងឆ្នាំ២០០៥ អាចទទួលយកបាន ។ ប៉ុន្តែអត្រាកម្រៃអាជ្ញាប័ណ្ណផលិតកម្មត្រូវប្តូរពី 1.60 រៀល មក 1.50 រៀល ក្នុង១គីឡូវ៉ាត់ម៉ោងថាមពលផលិតដែលជាអត្រាថ្មីសំរាប់អនុវត្តនៅក្នុងឆ្នាំការិយបរិច្ឆេទ២០០៥ តាមសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ០១៣សរ-០៥-អអក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ។

## ២.៥- ចំណាយផ្នែកចែកចាយ

EDCគិតចំណាយលើបុគ្គលិកស្មើនឹង 221,633,857 រៀល ក្នុងឆ្នាំ២០០៥ សំរាប់បុគ្គលិកចំនួន ៣៧នាក់ ដែលមានប្រាក់ខែជាមធ្យមប្រហែលនឹង 122USDក្នុង១នាក់ គឺមិនអាចទទួលយកបាន ។ អាជ្ញាធរអគ្គិសនីកម្ពុជា កំណត់យកអត្រាប្រាក់ខែជាមធ្យមស្មើនឹងអត្រាប្រាក់ខែផ្នែកផលិតកម្មដែលមានចំនួនប្រហែលនឹង 95USDក្នុង១នាក់ គឺស្មើនឹង 170,847,582 រៀលក្នុងឆ្នាំ២០០៥ ។ ចំណែកឯចំណាយដំណើរការនិងការថែទាំ ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ ស្មើនឹង 43,539,950 រៀល និង 98,017,873 រៀល ក្នុងឆ្នាំ២០០៥ អាចទទួលយកបាន ។ ប៉ុន្តែអត្រាកម្រៃអាជ្ញាប័ណ្ណចែកចាយត្រូវប្តូរពី 1.10 រៀល មក 0.90 រៀល ក្នុង១គីឡូវ៉ាត់ម៉ោងថាមពលលក់ ដែលជាអត្រាថ្មីសំរាប់អនុវត្តនៅក្នុងឆ្នាំការិយបរិច្ឆេទ២០០៥ តាមសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ០១៣សរ-០៥-អអក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ។

## ២.៦- ចំណាយផ្នែកហិរញ្ញវត្ថុ

EDCបានគិតចំណាយពន្ធអប្បបរមាស្មើនឹង 0.003 ដុល្លារ ក្នុង១គីឡូវ៉ាត់ម៉ោងផលិត គឺពុំត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធឡើយ ។ យោងតាមមាត្រា ២៤ នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ចែងថា ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា១ភាគរយលើផលរបរប្រចាំឆ្នាំរួមទាំងពន្ធអាករនានា ។ ដូច្នេះ អាជ្ញាធរកំណត់តាមអត្រា១ភាគរយនេះ ។

ការគណនាបំណុលពិបាកទារ គឺផ្អែកលើការអនុវត្តន៍ប្រមូលចំណូលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហើយកំរិតនៃបំណុលពិបាកទារនេះគឺជាចំនួនមួយដែលមិនអាចចៀសវាងបាន ឬអាចគណនាផ្អែកលើកំណើនឥណទេយ្យអតិថិជន (កំណើនប្រាក់ជំពាក់របស់អតិថិជន) ពីមួយឆ្នាំទៅមួយឆ្នាំ ។ ដោយសារអគ្គិសនីនៅទីរួមខេត្តកំពតគឺជាតំបន់ធ្វើសេវាកម្មថ្មីរបស់ EDC ពុំមានប្រតិបត្តិការក្នុងឆ្នាំកន្លងទៅទេ ដូច្នេះអាជ្ញាធរយកតួលេខដែលផ្តល់ដោយ EDC សំរាប់ការគណនាពេលនេះ ប៉ុន្តែត្រូវគិតអត្រា១ភាគរយនៃចំណូលពីការលក់ថាមពលប៉ុណ្ណោះ មិនមែនគិតលើចំណូលសរុបទេ ។ ដូចគ្នានេះដែរ សេវាធនាគារស្មើនឹង 2,000,000 រៀល ក្នុង១ឆ្នាំ អាចទទួលយកបានសំរាប់ការគណនាថ្លៃលក់អគ្គិសនីពេលនេះដែរ ។

អាជ្ញាធរពិនិត្យឃើញថា ថ្លៃភ្ជាប់ចរន្តមានកំរិតខ្ពស់នៅឆ្នាំដំបូង និងមានកំរិតទាបនៅឆ្នាំបន្តបន្ទាប់ទៀត ដូច្នេះ ដើម្បីចៀសវាងផលប៉ះពាល់ស្ថេរភាពហិរញ្ញវត្ថុ អាជ្ញាធរពុំយកថ្លៃភ្ជាប់ចរន្តមកសិក្សានៅពេលនេះទេ ។

## ៣-ការគណនាថ្លៃដើមអគ្គិសនី

ដោយផ្អែកលើការសង្កេតនិងកំណត់ខាងលើ ខ្ទង់ចំណាយទាំងឡាយរបស់អគ្គិសនីកម្ពុជានៅទីរួមខេត្តកំពតសំរាប់គណនាចំណាយត្រឹមត្រូវក្នុងកំឡុងឆ្នាំ២០០៥-២០០៧ មានដូចខាងក្រោម :

| បរិយាយ | | **2005** | **2006** | **2007** | សរុប |
|---|---|---|---|---|---|
| **១–ថាមពលផលិត** | គ.វ.ម៉ | 3,903,611 | 4,465,716 | 5,021,372 | 13,390,699 |
| **២–ថាមពលលក់** | គ.វ.ម៉ | 3,318,069 | 3,795,859 | 4,268,166 | 11,382,094 |
| **៣–ចំណាយផ្នែកផលិតកម្ម** | | | | | |
| ចំណាយទិញប្រេងម៉ាស៊ូត | រៀល | 1,781,334,808 | 2,037,840,182 | 2,291,402,685 | 6,110,577,675 |
| ចំណាយទិញប្រេងរំអិល | រៀល | 33,209,971 | 37,992,079 | 42,719,322 | 113,921,372 |
| កម្រៃអាជ្ញាប័ណ្ណផលិតកម្ម | រៀល | 5,855,417 | 6,698,574 | 7,532,058 | 20,086,049 |
| ចំណាយលើបុគ្គលិក | រៀល | 121,005,600 | 121,005,600 | 123,930,600 | 365,941,800 |
| ចំណាយដំណើរការនិងការថែទាំ | រៀល | 55,989,600 | 55,989,600 | 55,989,600 | 167,968,800 |
| ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ | រៀល | 65,345,249 | 74,639,517 | 83,827,152 | 223,811,918 |
| ចំណាយសំរាប់រំលោះអចលនទ្រព្យ | រៀល | 312,974,434 | 312,974,434 | 312,974,434 | 938,923,302 |
| ចំណាយការប្រាក់ | រៀល | 196,958,643 | 183,828,067 | 170,697,491 | 551,484,201 |
| ចំណាយផ្នែកផលិតកម្មសរុប | | 2,572,673,721 | 2,830,968,053 | 3,089,073,342 | 8,492,715,116 |
| **៤–ចំណាយផ្នែកចែកចាយ** | | | | | |
| ចំណាយលើបុគ្គលិក | រៀល | 170,487,582 | 170,487,582 | 174,608,682 | 515,583,846 |
| ចំណាយដំណើរការនិងការថែទាំ | រៀល | 43,539,950 | 43,539,950 | 43,539,950 | 130,619,850 |
| ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ | រៀល | 98,017,873 | 111,959,275 | 125,740,728 | 335,717,876 |
| ចំណាយសំរាប់រំលោះអចលនទ្រព្យ | រៀល | 304,073,541 | 304,073,541 | 304,073,541 | 912,220,624 |
| ចំណាយការប្រាក់ | រៀល | 260,017,949 | 242,683,419 | 225,348,889 | 728,050,257 |
| កម្រៃអាជ្ញាប័ណ្ណចែកចាយ | រៀល | 2,986,262 | 3,416,273 | 3,841,350 | 10,243,885 |
| ចំណាយផ្នែកចែកចាយសរុប | | 879,123,158 | 876,160,040 | 877,153,140 | 2,632,436,339 |
| **៥–ចំណាយហិរញ្ញវត្ថុ** | | | | | |
| ពន្ធអប្បបរមា | រៀល | 39,306,743 | 41,850,545 | 47,048,408 | 128,205,696 |
| បំណុលពិបាកទារ | រៀល | 36,498,763 | 41,754,445 | 46,949,828 | 125,203,036 |
| សេវាធនាគារ | រៀល | 2,000,000 | 2,000,000 | 2,000,000 | 6,000,000 |
| ចំណាយហិរញ្ញវត្ថុសរុប | | 77,805,506 | 85,604,989 | 95,998,236 | 259,408,731 |
| **៦–ចំណាយសរុប (៣ + ៤ + ៥)** | | 3,529,602,384 | 3,792,733,082 | 4,062,224,719 | 11,384,560,185 |
| **៧–ថ្លៃដើមអគ្គិសនីក្នុង១គីឡូវ៉ាត់ម៉ោង (៦ / ២ )** | | **1,064** | **999** | **952** | **1,000** |

## ៤-ការវាយតម្លៃរបស់នាយកដ្ឋានជំនាញ

យោងតាមលទ្ធផលនៃការគណនាខាងលើ ថ្លៃដើមអគ្គិសនីក្នុងកំឡុងពេលបីឆ្នាំ (២០០៥-២០០៧) ស្មើនឹង **1000** រៀល/kWh គឺជាថ្លៃដើមមួយសមរម្យអាចទទួលយកបាន ។

បើតាមយោបល់នាយកដ្ឋានជំនាញយល់ឃើញថា អគ្គិសនីកម្ពុជាស្នើសុំលក់ថ្លៃ **1,100**រៀល/kWh សំរាប់អ្នកប្រើប្រាស់ទូទៅ គឺជាថ្លៃលក់មួយអាចទទួលយកបាន បើប្រៀបធៀបទៅនឹងថ្លៃដើមអគ្គិសនី **1000** **រៀល/kWh** ។ ម្យ៉ាងទៀត ថ្លៃលក់នេះក៏ជាថ្លៃលក់មួយទាបជាងថ្លៃលក់របស់ក្រុមហ៊ុនអគ្គិសនីឯកជន នៅតាមទីរួមខេត្តមួយចំនួនដូចជានៅទីរួមខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិសាត់ ផងដែរ ។ ដូច្នេះ នាយកដ្ឋានជំនាញយល់ថាគួរកំណត់ថ្លៃលក់អគ្គិសនី **1,100**រៀល/kWh សំរាប់អ្នកប្រើប្រាស់ទូទៅនៅ ក្នុងតំបន់ធ្វើសេវាកម្មអគ្គិសនីរបស់អគ្គិសនីកម្ពុជានៅទីរួមខេត្តកំពត ។

ភ្នំពេញ, ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥

**ប្រធាននាយកដ្ឋាន**